ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខៈ..៥៩៥១.....សហវ

រាជរដ្ឋាភិបាល

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

លេខ: ១៩៧៦. ក.អ.ក/គ.ជ.នា

# ប្រកាសអន្តរក្រសួង

## ស្តីពី

## បែបបទ និងនីតិវិធីនៃការស្នើសុំនាំចូលឧបករណ៍ សម្ភារៈ គ្រឿងចក្រ យានយន្ត និង ផលិតផលគេលសិលា ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បកចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១-:**

ក្នុងគោលដៅពង្រឹងប្រសិទ្ធភាព និងបង្កើនល្បឿននៃយន្តការប្រជុំអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីពិនិត្យ និងដោះស្រាយសំណើនាំចូលឧបករណ៍ សម្ភារៈ គ្រឿងចក្រ យានយន្ត និងផលិតផលគេលសិលា ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ក្នុងក្របខ័ណ្ឌ ហិរញ្ញប្បទានឥតសំណង សម្រាប់អនុវត្តគម្រោង ឬ បម្រើក្នុងការិយាល័យរបស់ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ ភ្នាក់ងារអនុវត្តគម្រោង (រួមមាន ក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា និង/ឬ ស្ថាប័នផ្តល់ហិរញ្ញប្បទានឥតសំណងនៃដៃគូ អភិវឌ្ឍន៍ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល) ត្រូវមានកាតព្វកិច្ចផ្តល់ជាមុន ជូនមកក្រុមប្រឹក្សា អភិឌ្ឍន៍កម្ពុជា នូវឯកសារដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដូចខាងក្រោម ÷

ក- ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងនៃដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ :

១- កិច្ចព្រមព្រៀងក្របខ័ណ្ឌរវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ឬ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិ ។

២- កិច្ចព្រមព្រៀងដែលពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទាន រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ឬ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិ ឬ ឯកសារដទៃទៀតដែលមានតម្លៃប្រហាក់ប្រហែល ។

ខ- ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានរបស់អង្គការមិនមែនរដ្ឋាភិបាលៈ

១- លិខិតអនុញ្ញាតផ្លូវការពីក្រសួង ឬ ស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុញ្ញាត ឱ្យអង្គការមិនមែនរដ្ឋាភិបាលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- កិច្ចព្រមព្រៀងអនុវត្តគម្រោង និង/ឬ អនុស្សារណៈនៃការយោគយល់ រវាងក្រសួង ឬ ស្ថាប័ននៃ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាល ។

**ប្រការ២-:**

ចំពោះសំណើសុំនាំចូលជាក់ស្តែងនីមួយៗ នូវឧបករណ៍ សម្ភារៈ គ្រឿងចក្រ យានយន្ត និងផលិតផលគេលសិលា បន្ថែមលើឯកសារដែលមានចែងក្នុងប្រការ ១ ខាងលើ ភ្នាក់ងារអនុវត្តគម្រោងត្រូវផ្តល់ឯកសារបន្ថែម មក ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានដូចខាងក្រោម ÷

១- លិខិតស្នើសុំរបស់ប្រធាន ឬតំណាងស្របច្បាប់នៃភ្នាក់ងារអនុវត្តគម្រោង

២- ឯកសារគម្រោង និង/ឬ ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោង ។

៣- ផែនការសកម្មភាពការងារ និងថវិកាប្រចាំឆ្នាំ ប្រភពថវិកាសម្រាប់អនុវត្តគម្រោង ឬ ឯកសារ បញ្ជាក់ ដែលពាក់ព័ន្ធនឹងតម្រូវការនាំចូលឧបករណ៍ សម្ភារៈ គ្រឿងចក្រ យានយន្ត និងផលិតផល គេលសិលា ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ។

៤- របាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តគម្រោង ។

៥- បញ្ជីយានយន្ត និងគ្រឿងចក្រ ដែលបានអនុញ្ញាតឱ្យនាំចូលកន្លងមក និងស្ថានភាពបច្ចុប្បន្នរបស់យានយន្ត និងគ្រឿងចក្រទាំងនោះ ។

៦- ឯកសារពាក់ព័ន្ធនឹងការនាំចូល រួមមាន :

- វិក្ក័យប័ត្រទំនិញ
- បញ្ជីវេចខ្ចប់
- ឯកសារដឹកជញ្ជូន

ចំពោះអំណោយមនុស្សធម៌ដែលមានលក្ខណៈមួងម្កាល ត្រូវមានលិខិតបញ្ជាក់ពីម្ចាស់អំណោយ បន្ថែមលើឯកសារពាក់ព័ន្ធនឹងការនាំចូល ដូចមានចែងក្នុងចំណុច ៦ ខាងលើ ។

**ប្រការ៣-:**

ចំពោះការនាំចូលរថយន្តដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ សម្រាប់អនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ ឬ សម្រាប់បំរើការនៅការិយាល័យនៃភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង រាជរដ្ឋាភិបាលអនុញ្ញាតឱ្យនាំចូល នូវរថយន្តដែលបំពាក់ឧបករណ៍បច្ចេកទេសតាមស្តង់ដាររបស់ការិយាល័យផ្តល់សេវាសម្រាប់គម្រោងនៃអង្គការសហប្រជាជាតិ ។ ប្រសិនបើការស្នើនាំចូលរថយន្តលើសពីស្តង់ដានេះ អ្នកស្នើសុំនាំចូលត្រូវបញ្ជាក់អំពីមូលហេតុនៃតម្រូវការឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៤-:**

ចំពោះការនាំចូលរថយន្តដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ របស់អង្គការមិនមែនរដ្ឋាភិបាល សម្រាប់អនុវត្តគម្រោង ឬ សម្រាប់បំរើការនៅការិយាល័យរបស់ខ្លួន ត្រូវស្នើសុំគោលការណ៍ឯកភាពជាមុន ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មុននឹងធ្វើការបញ្ជាទិញ ។ ក្នុងការស្នើសុំគោលការណ៍នេះ សាមីអង្គការត្រូវភ្ជាប់មកជាមួយនឹងលិខិតស្នើសុំ នូវឯកសារដែលបញ្ជាក់អំពីយថាប្រភេទក្នុងវិក្កយប័ត្របណ្តោះអាសន្ន ។ រាជរដ្ឋាភិបាលមិនអនុញ្ញាតឱ្យនាំចូលរថយន្តប្រភេទទេសចរណ៍ប្រណីត (លេខកូដសម្គាល់ ៨៧០៣) ឬ រថយន្តដែលមានតម្លៃចាប់ពី ៣០.០០០ដុល្លាអាមេរិក ឡើង ។ ប្រសិនបើនាំចូលរថយន្តប្រភេទទេសចរណ៍ប្រណីត (លេខកូដសម្គាល់ ៨៧០៣) ឬ រថយន្តដែលមានតម្លៃខ្ពស់ជាង ៣០.០០០ដុល្លាអាមេរិក សាមីអង្គការត្រូវបញ្ជាក់អំពីមូលហេតុនៃតម្រូវការឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៥-:**

ឧបករណ៍ សម្ភារៈ គ្រឿងចក្រ យានយន្ត និងផលិតផលគេលសិលា ដែលបាននាំចូលដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ មិនត្រូវបានអនុញ្ញាតឱ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់ផ្សេងពីគម្យដ្ឋានដែលបានអនុគ្រោះ ឬ បោះបង់ចោល ដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

**ប្រការ៦-:**

ដើម្បីធានាប្រសិទ្ធភាពជុំវិញការអនុញ្ញាតឱ្យនាំចូលដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ លើឧបករណ៍ សម្ភារៈ គ្រឿងចក្រ យានយន្ត និងផលិតផលតេលសិលា និងដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តគម្រោង យន្តការប្រជុំអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចចុះធ្វើការត្រួតពិនិត្យការអនុវត្តគម្រោងដល់ទីកន្លែង ក្នុងករណីចាំបាច់ ។

**ប្រការ៧-:**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨-:**

អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួង និងស្ថាប័នអនុវត្តគម្រោង ដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**គាត ឈន់**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ ៨ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ